00204366

C2/I/60

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**សំណុំរឿងព្រហ្មទណ្ឌលេខ** : ០០២/១៩-០៩-២០០៧-អ.វ.ត.ក/កសចស(អបជ០៣)

**ដាក់ជូន** : អង្គបុរេជំនុំជម្រះ

**កាលបរិច្ឆេទដាក់ជូន** : ១៧ កក្កដា ឆ្នាំ២០០៨

**ភាគីដាក់ឯកសារ** : សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

**ភាសាដើម** : ខ្មែរ និង អង់គ្លេស

**ប្រភេទឯកសារ** : សាធារណៈ

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 07 / 2008
ម៉ោង (Time/Heure): 10:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

---

**ការកត់សម្គាល់រួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**លើពាក្យសុំការពិចារណាឡើងវិញ**

**អំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យទៅកាន់អង្គជំនុំជម្រះ**

<u>ដាក់ជូនដោយ</u>

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី:**

លោក ហុង គឹមសួន

លោក យុង ផានិត

លោក គង់ ពិសី

លោក ឡោ ជុនធី

លោក នី ចាន់ឌី

លោកស្រី Silke Studzinsky

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 17 / 07 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

<u>ចែកជូន:</u>

**អង្គបុរេជំនុំជម្រះ:**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ហ្នួត វុទ្ធី

ចៅក្រម Rowan DOWNING

ចៅក្រម ន័យ ថុល

ចៅក្រម Katinka LAHUIS

**ការិយាល័យសហព្រះរាជអាជ្ញា:**

លោកស្រី ជា លាង

លោក Robert PETIT

**សហមេធាវីរបស់អៀង សារី**

លោក អាង ឧត្តម

លោក Michael Karnavas

**<u>ចំលងជូន:</u>**

**សហមេធាវីរបស់ កាំង ហ្គេកអ៊ាវ**

លោក ការ សាវុត្ថ

លោក François Roux

**សហមេធាវីរបស់ នួន ជា**

លោក សុន អារុណ

លោក Michel Pestman

លោក Victor Koppe

**សហមេធាវីរបស់ ខៀវ សំផន**

លោក សាយ បូរី

លោក Jacques Vergès

**សហមេធាវីរបស់ អៀង ធីរិទ្ធ**

លោក លោក ផាត់ ពៅស៊ាង

លោកស្រី Diana Ellis

## ១. សេចក្តីផ្តើម

១. កាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះ (“អបជ”) បានចេញសេចក្តីសម្រេចមួយលើបញ្ហាបឋមទាំងឡាយ ដែលបានលើកឡើងដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី (“សេចក្តីសម្រេចលើបញ្ហាបឋម”) ដោយបដិសេធចោលនូវសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ដែលបានស្នើសុំ *“ថ្លែងប្រាស្រ័យដោយផ្ទាល់បើទោះបីជាមានមេធាវីតំណាងហើយក្តី។”*[1]

អង្គបុរេជំនុំជម្រះបានយោងទៅលើសេចក្តីសម្រេចកន្លងមករបស់ខ្លួន[2] ហើយបានសម្រេចតំកលនូវការយល់ឃើញរបស់ខ្លួនដោយយោងទៅលើវិធាន ៧៧(១០) នៃវិធានផ្ទៃក្នុង។

២. នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ បន្ទាប់ពីបានទទួលសេចក្តីសម្រេចខាងលើ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានឈប់ពឹងពាក់មេធាវីរបស់ខ្លួន ហើយបានស្នើសុំថ្លែងប្រាស្រ័យដោយខ្លួនឯងរយៈពេល១០នាទី ដែលរយៈពេលនេះស្ថិតនៅក្នុងថេរវេលាកំណត់ដែលអង្គបុរេជំនុំជម្រះបានផ្តល់ឱ្យខាងភាគីដើមបណ្តឹរដ្ឋប្បវេណី ហើយនិយាយពាក់ព័ន្ធតែទៅលើបញ្ហានៃការអនុវត្តគោលការណ៍គ្មានការកាត់ទោសពីរដង *(ne bis in idem)*។ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចមួយទៀត[3] (*“សេចក្តីសម្រេចស្តីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មានមេធាវីតំណាង”*) ហើយក៏បានបដិសេធសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី

---

[1] សំណុំរឿងរបស់ អៀង សារី លេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-កសចស(អបជ០៣) សេចក្តីសម្រេចលើបញ្ហាបឋម ដែលលើកឡើងដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្នុងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាឃុំខ្លួនបណ្តោះអាសន្នកថាខ័ណ្ឌទី៧ ERN:00198102-00198104។

[2] សំណុំរឿងរបស់ អៀង ធីរិទ្ធ លេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-កសចស-(អបជ០២) សេចក្តីណែនាំចំពោះការជូនសម្អាងផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងពេលសវនាការលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០០៨ ERN 00189459-00189460 ឯកសារលេខ C 20/I/21។

[3] សំណុំរឿងរបស់ អៀង សារី លេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-កសចស(អបជ០៣) សេចក្តីសម្រេចចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីសំណើសុំថ្លែងប្រាស្រ័យដោយផ្ទាល់ទៅកាន់តុលាការរបស់ដើមបណ្តឹងរដ្ឋប្បវេណី ERN:00198495-00198497។

ក្នុងការថ្លែងប្រាស្រ័យទៅកាន់ តុលាការដោយផ្ទាល់។
អង្គបុរេជំនុំជម្រះបានយោងជាថ្មីទៅលើវិធាន៧៧(១០)នៃវិធានផ្ទៃក្នុង និងបានយល់ឃើញថា *"[....] បទប្បញ្ញត្តិជាក់លាក់មានចែងក្នុងវិធានផ្ទៃក្នុង ស្តីអំពីនីតិវិធីក្នុងដំណាក់កាលមុនអង្គសេចក្តីពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ខ្លួន។* អង្គបុរេជំនុំជម្រះក៏យល់ឃើញផងដែរថា *វិធាន៧៧(១០)មានន័យថា មានតែមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះដែលមានសិទ្ធិធ្វើការកត់សម្គាល់សង្ខេបផ្ទាល់មាត់ ក្នុងបណ្តឹងឧទ្ធរណ៍មុនអង្គសេចក្តី។"*

៣. ចៅក្រម Rowan Downing បានចេញនូវគំនិតជំទាស់ដោយឡែកមួយ[4] និងបានបង្ហាញទស្សនៈរបស់ខ្លួនថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះគួរត្រូវបានផ្តល់សិទ្ធិឱ្យថ្លែងប្រាស្រ័យទៅកាន់តុលាការដោយផ្ទាល់ខ្លួន។ គាត់បានលើកឡើងពីភាពផ្ទុយគ្នារវាងវិធាន៧៧(១០)នៃវិធានផ្ទៃក្នុង ដែលហាក់ដូចជាមានលក្ខណៈរិតត្បិត ដោយលើកឡើងតែពីសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលអាចធ្វើការកត់សម្គាល់នៅមុខអង្គបុរេជំនុំជម្រះបាន និងវិធាន២៣ នៃវិធានផ្ទៃក្នុងដដែលនេះ ដែលផ្តល់សិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួម។
ម្យ៉ាងវិញទៀត លោកចៅក្រមរូបនេះក៏យល់ឃើញថា យោងតាមវិធាន២១(១)(ក) "វានឹងមិនយុត្តិធម៌ទេ [....] ក្នុងការមិនអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីថ្លែងប្រាស្រ័យទៅកាន់តុលាការនោះ"។

៤. នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៨ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានដាក់ពាក្យសុំ[5] ការពិចារណាឡើងវិញលើសេចក្តីសម្រេចស្តីពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាង ("ពាក្យសុំ")។ ពាក្យសុំនេះបានដាក់ជូនយ៉ាងត្រឹមត្រូវនៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៨។ ពាក្យសុំនេះបង្ហាញនូវអង្គហេតុបន្ថែម ពាក់ព័ន្ធនឹងការប្រគល់សិទ្ធិឱ្យមេធាវីពីដំបូងរបស់គាត់

---

[4] សូមមើល លេខយោងទី៣ ខាងលើ ទំព័រ៣។

[5] សំណុំរឿងរបស់ អៀង សារី លេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-កសចស(អបជ០៣) ពាក្យសុំការពិចារណាឡើងវិញលើសិទ្ធិរបស់ដើមបណ្តឹងក្នុងការថ្លែងប្រាស្រ័យដោយផ្ទាល់ទៅកាន់អង្គបុរេជំនុំជម្រះ ERN:00198482-00198487។

00204370



ដែលពេលនោះ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ តាមរយៈឯកសារប្រគល់សិទ្ធិនេះ បានបញ្ជាក់យ៉ាងច្បាស់ជូនទៅសហចៅក្រមស៊ើបអង្កេតថាខ្លួនប្រាថ្នាចង់តំណាងឱ្យខ្លួនឯងផង និងតំណាងដោយមេធាវីរបស់ខ្លួនផង។ ដូច្នេះ គាត់មិនបានបោះបង់សិទ្ធិរបស់ខ្លួនក្នុងការតំណាងឱ្យខ្លួនឯង តាមរយៈការចុះហត្ថលេខាប្រគល់សិទ្ធិដល់មេធាវីនោះឡើយ។

៥. សវនាការបានបញ្ចប់នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨។

## ២. វិសាលភាពនៃពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី

៦. ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានដាក់សំណើរបស់ខ្លួន សុំថ្លែងប្រាស្រ័យដោយផ្ទាល់ខ្លួនកាលពីថ្ងៃទី ២ ខែកក្កដា ឆ្នាំ២០០៨ជាភាសាអង់គ្លេស។ ក្រោយមកនៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៨ ពាក្យសុំនោះត្រូវបានដាក់ជូនជាពីរភាសាយ៉ាងត្រឹមត្រូវតាមសេចក្តីណែនាំអនុវត្តរបស់តុលាការ។ នៅខណៈពេលដាក់ឯកសារនេះ(មិនទាន់មានសុពលភាពឡើយ) កាលពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៨ ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យពិចារណាឡើងវិញលើសេចក្តីសម្រេចស្តីពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាង និងដើម្បីអនុញ្ញាតឲ្យគាត់អាចបង្ហាញការកត់សម្គាល់របស់ខ្លួនលើបញ្ហា *គោលការណ៍គ្មានការកាត់ទោសពីរដង*។

៧. អង្គបុរេជំនុំជម្រះនៅពេលនេះយល់ឃើញថា ពាក្យសុំនៅដំណាក់កាលនេះ ពោលគឺបន្ទាប់ពីសវនាការបានបញ្ចប់ ជាសំណើសុំបើកសវនាការឡើងវិញដើម្បីស្តាប់ដើមបណ្តឹងរដ្ឋប្បវេណី។

៨. ប៉ុន្តែផ្ទុយទៅវិញ យើងខ្ញុំសូមបញ្ជាក់ថា ពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះគួរត្រូវបានយល់ថាជាការស្វះស្វែងរកសេចក្តីសម្រេចជាទូទៅមួយ (declaratory decision) ស្តីពីសិទ្ធិចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅមុខអង្គបុរេជំនុំជម្រះ ជាជាងការស្នើសុំឱ្យបើកសវនាការឡើងវិញ។

ដើមបណ្តឹងរដ្ឋប្បវេណីមានផលប្រយោជន៍តាមផ្លូវច្បាប់ ដែលបញ្ហានេះត្រូវបានសម្រេចដោយអង្គបុរេជំនុំជម្រះ។

៩. ជាទូទៅ ប្រសិនបើសេចក្តីសម្រេចលើសំណើមួយហួសពេលទៅហើយ ហើយមានហានិភ័យនៃការកើតឡើងវិញនូវស្ថានភាពនៃការរំលោភសិទ្ធិនោះ ភាគីមួយអាចស្វះស្វែងរកដំណោះស្រាយប៉ះប៉ូវវិញ តាមរយៈការទទួលបានសេចក្តីសម្រេចជាទូទៅមួយដើម្បីកំណត់ពីសិទ្ធិរបស់ខ្លួន។

ដូច្នេះ នៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ ពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីគួរត្រូវបានធ្វេងយល់ថាជាសំណើមួយដើម្បីសុំប្រកាសជាទូទៅថា ទាំងវិធានផ្ទៃក្នុង និងទាំងស្មារតីនៃគោលការណ៍ទូទៅនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឱ្យតំណាងដោយខ្លួនឯងទោះមាន ឬគ្មានមេធាវីនៅមុខអង្គបុរេជំនុំជម្រះ។

១០. ដោយសារសវនាការបានបញ្ចប់ទៅហើយ ការបើកសវនាការឡើងវិញនឹងជាការបង់ខាតពេលវេលា កម្លាំង និងធនធាន។ម្យ៉ាងវិញទៀត ដោយសំណើសុំដែលមានសុពលភាពត្រូវបានដាក់ជូនបន្ទាប់ពីសវនាការ ដូច្នេះវាមិនមែនជាការសមស្រប ឬត្រឹមត្រូវនោះទេក្នុងការបើកសវនាការឡើងវិញ។ ដើមបណ្តឹងរដ្ឋប្បវេណីចង់បានការកាត់ក្តីមួយឆាប់រហ័ស។ ហេតុដូចនេះហើយ នៅក្នុងដំណាក់កាលនេះ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសវនាការរបស់អង្គបុរេជំនុំជម្រះគួរត្រូវបានកំណត់ជាសេចក្តីសម្រេចតាមផ្លូវច្បាប់ជាទូទៅមួយដើម្បីប៉ះប៉ូវចំពោះពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

**៣. ច្បាប់ពាក់ព័ន្ធ**

១១. វិធាន២៣(១)នៃវិធានផ្ទៃក្នុងជាវិធានមូលដ្ឋាន ពាក់ព័ន្ធនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធីនៅមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ វិធាននេះចែងថា៖

"១. គោលបំណងនៃបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បី ៖
ក-ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុង យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់ និង
ខ-[...]"

វិធាននេះមិនចែងពីភាពខុសប្លែកគ្នា រវាងសកម្មភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធី លើអង្គសេចក្តី និងកិច្ចដំណើរការនីតិវិធីនៅមុនអង្គសេចក្តីឡើយ។

វិធានទី២៣(៧) នៃវិធានផ្ទៃក្នុងចែងថា៖

"ជនរងគ្រោះដែលចូលរួមក្នុងនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិត្រូវបានតំណាងដោយមេធាវីជាតិ ឬអន្តរជាតិដោយសហការជាមួយមេធាវីជាតិតាមនីតិវិធីដូចខាងក្រោម:[...]"

វិធាន ២១ នៃវិធានផ្ទៃក្នុងចែងថា៖

"ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទនិង ជនរងគ្រោះ [....] ក្នុងបរិបទនេះ៖
ក-ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ [....]"

## ៤. ឧឡឹករណ៍

១២. អង្គបុរេជំនុំជម្រះបានផ្តល់សម្អាងហេតុនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ស្តីពីសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មានមេធាវីតំណាង កាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ថា ការមិនឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការកត់សម្គាល់ផ្ទាល់មាត់ គឺដោយសារលក្ខខណ្ឌតម្រូវដូចមានចែងនៅក្នុងវិធាន៧៧(១០) នៃវិធានផ្ទៃក្នុង: *"ប្រព័ន្ធវិធានផ្ទៃក្នុងគឺចែងយ៉ាងច្បាស់លាស់។ បទប្បញ្ញត្តិជាក់លាក់មានចែងនៅក្នុងវិធានផ្ទៃក្នុងសម្រាប់ដំណាក់កាលមុនអង្គសេចក្តី ដែលទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីនិងមេធាវីរបស់ពួកគេ។ វិធាន៧៧(១០) នៃវិធានផ្ទៃក្នុង ចែងថាមានតែមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ ដែលមានសិទ្ធិធ្វើការកត់សម្គាល់សង្ខេបផ្ទាល់មាត់ក្នុងអំឡុងពេលប្តឹងឧទ្ធរណ៍នៅដំណាក់កាលមុនអង្គសេចក្តី។"*[6]

អង្គបុរេជំនុំជម្រះបានយោងទាំងស្រុងលើបទប្បញ្ញត្តិដែលមានចែងនៅក្នុងប្រយោគនៃវិធាន៧៧(១០)នៃវិធានផ្ទៃក្នុងខាងក្រោមនេះថា៖

> "បន្ទាប់ពីសហចៅក្រមរបាយការណ៍បានអានរបាយការណ៍ សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីអាចធ្វើការកត់សម្គាល់ដោយសង្ខេបរបស់ខ្លួន។"

១៣. ដោយសារតែនៅក្នុងបញ្ញត្តិនេះមានចែងតែករណីមេធាវីរបស់ភាគី អង្គបុរេជំនុំជម្រះសន្និដ្ឋានថាមិនមានការចូលរួមដោយផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ ប៉ុន្តែ យើងជឿជាក់ថាទស្សនៈច្បាប់នេះ ផ្អែកលើការបកស្រាយមាត្រា៧៧(១០)ក្នុងន័យចង្អៀត ដែលផ្ទុយទៅនឹងរបៀបនៃការបកស្រាយវិធានផ្ទៃក្នុងផ្សេងៗទៀត និងមិនទទួលស្គាល់អំពីចន្លោះប្រហោងក្នុងការពង្រាងវិធាន៧៧(១០) នៃវិធានផ្ទៃក្នុង។ ប្រសិនបើកិច្ចដំណើរការនីតិវិធីផ្អែកលើន័យត្រង់នៃបទបញ្ញត្តិរបស់វិធាន៧៧(១០)នៃវិធានផ្ទៃក្នុង ម្ចាស់បណ្តឹងឧទ្ធរណ៍ខ្លួនឯងផ្ទាល់ក៏នឹងត្រូវបានគេហាមឃាត់មិនឲ្យឡើងថ្លែងប្រាស្រ័យផ្ទាល់មាត់ដែរ។ អង្គបុរេជំនុំជម្រះបានអនុវត្ត

---

[6] សូមមើលលេខយោងទី៣ ខាងលើ ទំព័រទី២ កថាខណ្ឌទី៣

យ៉ាងត្រឹមត្រូវនៅពេលដែលអង្គបុរេជំនុំជម្រះមិនប្រកាន់ជំហរផ្លូវច្បាប់បែបនេះ ហើយបានអនុញ្ញាតឲ្យលោក អៀង សារីនិយាយនៅក្នុងសវនាការកាលពីថ្ងៃទី៣០ខែមិថុនា ឆ្នាំ២០០៨ ។ នៅក្នុងប្រព័ន្ធនៃវិធានផ្ទៃក្នុងនានា ក៏នៅមានភាពផ្ទុយគ្នាផ្សេងៗទៀត ដែលបញ្ជាក់ថាវិធានទាំងនេះ មិនមានភាពច្បាស់លាស់ដូចដែលបានលើកឡើងនៅក្នុងសេចក្ដីសម្រេចលើសិទ្ធិដើមបណ្ដឹងរដ្ឋប្បវេណីដែលគ្មានមេធាវីតំណាង។[7]

១៤. យោងតាមវិធាន២៣(៧)នៃវិធានផ្ទៃក្នុង ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិត្រូវបានតំណាងដោយមេធាវី។ ដោយសារតែវិធាននេះលើកឡើងអំពីសិទ្ធិមានអ្នកតំណាងផ្នែកច្បាប់ ក៏ប៉ុន្តែមិនបានលើកឡើងអំពីកាតព្វកិច្ចត្រូវមានអ្នកតំណាងផ្នែកច្បាប់ ដូច្នេះវាពិតប្រាកដណាស់ថា ដើមបណ្ដឹងរដ្ឋប្បវេណីអាចចូលរួមក្នុងសវនាការដោយខ្លួនឯងផ្ទាល់ ដោយមិនបាច់មានអ្នកតំណាងផ្នែកច្បាប់នៅគ្រប់ដំណាក់ការនៃដំណើរការនីតិវិធីនោះទេ។ យើងយល់ឃើញថា ការចូលរួមអាចមានន័យទៅបាន លុះណាតែដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឲ្យឡើងថ្លែងប្រាស្រ័យផ្ទាល់មាត់ក្នុងអំឡុងពេលដំណើរការនីតិវិធីមុនអង្គសេចក្ដី។ ការមិនអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីចូលរួមក្នុងកិច្ចនីតិវិធីទាំងនោះ គឺជាការកម្រិតសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានចែងនៅក្នុងវិធាន២៣(១) នៃវិធានផ្ទៃក្នុង ដែលក្នុងវិធាននោះមិនមានចែងអំពីការកម្រិតសិទ្ធិក្នុងការចូលរួមរបស់ដើមរដ្ឋប្បវេណីនោះទេ។ បន្ថែមពីលើនេះទៀត អង្គបុរេជំនុំជម្រះបានគាំទ្រនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន[8] លើសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដោយលើកឡើងថា ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងបណ្ដឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្ដោះអាសន្ន។ ជាការពិតណាស់ សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះកាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ មានន័យថា ដើមបណ្ដឹងរដ្ឋវេណីមានកាតព្វកិច្ចត្រូវ

---

[7] ឧទាហរណ៍ក្នុងវិធាន៩៤(១) (ក) វិធានផ្ទៃក្នុងអនុញ្ញាតឲ្យតែមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីប៉ុណ្ណោះ ដើម្បីធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។ ផ្ទុយមកវិញ វិធាន៩៤(២) នៃវិធានផ្ទៃក្នុងអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីធ្វើសេចក្ដីសន្និដ្ឋានឆ្លើយតបទៅនឹងសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ភាគីផ្សេងៗទៀត។ បន្ថែមពីលើនេះវិធាននេះគឺផ្ទុយទៅនឹងមាត្រា៣៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលក្រមនេះអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីនិងមេធាវីរបស់ពួកគេធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។

[8] រឿងក្ដីរបស់នួន ជា លេខ:០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ០១) ERN 00172886-00172906;C11/53

តែមានអ្នកតំណាង ដើម្បីទទួលបានសិទ្ធិក្នុងការចូលរួមរបស់ខ្លួន។ ផលវិបាកនៃការសម្រេចនេះ គឺវាផ្ទុយទាំងស្រុងនឹងវិធាន២៣(៧) នៃវិធានផ្ទៃក្នុង ដែលវិធាននោះគ្រាន់តែផ្តល់នូវសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីឱ្យមានមេធាវីតំណាងតែប៉ុណ្ណោះ។

១៥. ដរាបណាអ.វ.ត.ក មិនផ្តល់ថវិកាឱ្យដើមបណ្តឹងរដ្ឋវេណីមានអ្នកតំណាងផ្នែកច្បាប់នោះទេ វាមិនមានភាពយុត្តិធម៌នោះទេ ដែលអង្គបុរេជំនុំជម្រះតម្រូវឱ្យដើមបណ្តឹងរដ្ឋប្បវេណីអនុវត្តនូវសិទ្ធិរបស់ខ្លួនតាមរយៈសហមេធាវី។

១៦. ប៉ុន្តែ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីបានជ្រើសរើសមេធាវីតំណាងខ្លួន វាមិនមែនមានន័យថា គាត់បានបោះបង់សិទ្ធិក្នុងការនិយាយរបស់គាត់នៅក្នុងសវនាការ ដូចដែលមានចែងនៅក្នុងវិធាន២៣(១) នៃវិធានផ្ទៃក្នុងទេ។ អ្នកពង្រាងវិធានផ្ទៃក្នុង មានបំណងចង់ឱ្យអ្នកតំណាងផ្នែកច្បាប់ធ្វើយ៉ាងណាឱ្យឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីកាន់តែប្រសើរឡើង ដូច្នេះវិធាន២៣(១) នៃវិធានផ្ទៃក្នុង មិនគួរបកស្រាយក្នុងន័យចង្អៀតដោយមិនឱ្យមានការចូលរួមដោយខ្លួនឯង និងការចូលរួមដោយផ្ទាល់ពីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការនោះទេ។[9]

១៧. ដូច្នេះ សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីជូនសម្អាងថា អង្គបុរេជំនុំជម្រះគួរតែបកស្រាយបទប្បញ្ញត្តិដែលផ្ទុយគ្នានៅក្នុងវិធាន៧៧(១០) នៃវិធានផ្ទៃក្នុង តាមលក្ខណៈប្រព័ន្ធនិងទ្រឹស្តី teleological ដែលបទប្បញ្ញត្តិនោះត្រូវបកស្រាយដោយឈរលើគោលការណ៍ ទូទៅក្នុងការផ្តល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីនូវសិទ្ធិចូលរួមក្នុងនីតិវិធីពេញលេញជាភាគី។

១៨. ជាចុងក្រោយ វិធីសាស្ត្រនៃការបកស្រាយនេះ ដែលយើងខ្ញុំស្នើឡើង ត្រូវបានគាំទ្រដោយវិធាន២១(១) នៃវិធានផ្ទៃក្នុង ដែលវិធាននេះបានផ្តល់ការណែនាំជាទូទៅអំពីរបៀបនៃការបកស្រាយច្បាប់ដែលពាក់ព័ន្ធដោយបានចែងថា ដំណើរការនីតិវិធីត្រូវតែអនុវត្តដោយភាពយុត្តិធម៌

[9] នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ឧទាហរណ៍ដូចជាប្រទេសបារាំង ប្រទេសអាឡឺម៉ង់ និងប្រទេសអ៊ីតាលី ភាគីដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមយ៉ាងសកម្ម និងមានសិទ្ធិនិយាយបន្ថែមលើមេធាវីរបស់ពួកគេ។ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានបាត់បង់សិទ្ធិរបស់ពួកគេបន្ទាប់ពីចុះហត្ថលេខាលើលិខិតប្រគល់សិទ្ធិដល់មេធាវីតំណាងដោយអាណត្តិនោះទេ។

00204376

C22/I/160



ក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនត្រូវចោទ និងជនរងគ្រោះ។ ដោយសារអង្គបុរេជំនុំជម្រះបានគោរពតាមសេចក្តីណែនាំ អំពីការបកស្រាយទាក់ទងនឹងសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដូច្នេះអង្គបុរេជំនុំជម្រះគួរតែគោរពនូវសិទ្ធិរបស់ជនរងគ្រោះក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។

១៩. ដើម្បីជៀសវាងការបង្ហាញខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះមុខតុលាការដោយគ្មានអ្នកតំណាងផ្នែកច្បាប់ ឬដើម្បីជៀសវាងការឈប់ពឹងពាក់មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងគោលបំណងចូលរួមក្នុងការនិយាយនៅក្នុងសវនាការ អង្គបុរេជំនុំជម្រះគួរតែញែកឲ្យច្បាស់លើដើមបណ្តឹងរដ្ឋប្បវេណីដែលមានមេធាវីតំណាង និងដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មានមេធាវីតំណាង។

២០. សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីសង្កេតឃើញថា សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះកាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ បានបង្ហាញថា អង្គបុរេជំនុំជម្រះបារម្ភអំពីលទ្ធភាពនៃការកើនឡើងនៃចំនួនដើមបណ្តឹងរដ្ឋប្បវេណី ដែលអាចនាំឲ្យរាំងស្ទះដល់ដំណើរការនីតិវិធីជាពិសេស ប្រសិនបើអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងការសន្និដ្ឋានផ្ទាល់មាត់ដោយខ្លួនឯងនិងដោយផ្ទាល់។

២១. ប៉ុន្តែ ការបារម្ភអំពីបញ្ហានេះ មិនមានភាពត្រឹមត្រូវនោះទេ។ សហមេធាវីរបស់ដើមបណ្តឹងរដ្ឋ-ប្បវេណីគាំទ្រយ៉ាងពេញទំហឹងលើគំនិត *បទបញ្ជាកំណត់ពេលវេលា* ក្នុងអំឡុងពេលសវនាការ ហើយយើងយល់ថា វាជាភារកិច្ចចាំបាច់របស់ខ្លួនក្នុងការសម្របសម្រួលសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើមានដើមបណ្តឹងរដ្ឋប្បវេណីច្រើន។ នៅពេលដែលមានការកំណត់នូវពេលវេលាទាំងមូល សម្រាប់ការចូលរួមដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ការធ្វើសេចក្តីសន្និដ្ឋានដោយដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ឬមួយចំនួនមិនអាចនាំឲ្យមានការពន្យារពេលសវនាការនោះទេ។ វាជាការចាំបាច់ដែលអង្គបុរេជំនុំជម្រះត្រូវដាក់បទបញ្ជាក្នុងដំណើរការនីតិវិធី និងបង្កើតនូវការកំណត់ពេលវេលា ចំនួនទំព័រ និងប្រធានបទក្នុងអំឡុងពេលសវនាការ។ នៅក្នុងវិសាលភាពនេះ ដើមបណ្តឹងរដ្ឋប្បវេណី

និងសហមេធាវីរបស់ពួកគេ នឹងមានទំនួលខុសត្រូវពេញទីក្នុងការរៀបចំសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ខ្លួនក្នុងតាមការកំណត់។

## ២២. សេចក្តីសន្និដ្ឋាន

ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនីតិវិធី ដែលរួមទាំងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយផ្ទាល់ខ្លួន។ ដើមបណ្តឹងរដ្ឋប្បវេណីនៅតែមានសិទ្ធិថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយផ្ទាល់ខ្លួន ទោះបីជាពួកគេមានមេធាវីតំណាងក៏ដោយ។ អង្គបុរេជំនុំជម្រះគួរឆ្វេងយល់ថា ពាក្យសុំនេះ ជាសំណើដើម្បីសុំសេចក្តីសម្រេចជាឧទ្ទារិកមួយ។

ហេតុដូចនេះហើយ សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីសូមគោរពស្នើសុំ៖

១. បញ្ជាក់ថា ពាក្យសុំនោះជាសំណើសុំកំណត់សិទ្ធិចូលរួមជាទូទៅរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

២. ប្រកាសថា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយផ្ទាល់ខ្លួន ទោះដើមបណ្តឹងរដ្ឋប្បវេណីមានឬគ្មានមេធាវីតំណាងក៏ដោយ។

C22/I/160

០០២/១៩-០៩-២០០៧-អ.វ.ត.ក/កសចស(អបជ០៣)

**ដាក់ជូនដោយក្ដីគោរពពី**

**សហមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី**

មេធាវី **ហុង គឹមសួន**
មេធាវីរបស់គម្រោងអ្នកការពារក្ដីកម្ពុជា

មេធាវី **ឡោ ជុនធី**
មេធាវីរបស់ជំនួយផ្នែកច្បាប់កម្ពុជា

មេធាវី **យុង ផានិត**
មេធាវីរបស់គម្រោងអ្នកការពារក្ដីកម្ពុជា

មេធាវី **នី ចាន់ឌី**
មេធាវីរបស់ជំនួយផ្នែកច្បាប់កម្ពុជា

មេធាវី **គង់ ពិសី**
មេធាវីរបស់គម្រោងអ្នកការពារក្ដីកម្ពុជា

មេធាវី Silke Studzinsky
មេធាវី